**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្តីការគណៈរដ្ឋមន្ត្រី**

**លេខៈ ០១ អ៣ស**

# សេចក្តីណែនាំ

## ស្តីពី

## ការពង្រឹងនីតិវិធីអនុវត្តតារាងទូទាត់បៀវត្សតាមប្រព័ន្ធព័ត៌មានវិទ្យា

តារាងទូទាត់បៀវត្សតាមប្រព័ន្ធព័ត៌មានវិទ្យា ត្រូវបានដាក់ឲ្យអនុវត្តចាប់តាំងពីឆ្នាំ២០០១ តាមស្មារតីនៃសេចក្តីជូនដំណឹងលេខ០៣៣/០១ សជណ ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០០១ របស់ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល ស្តីពីការអនុវត្តអនុក្រឹត្យលុបឈ្មោះមន្ត្រីរាជការ និងការដាក់ឲ្យអនុវត្តតារាងទូទាត់បៀវត្សតាមប្រព័ន្ធព័ត៌មានវិទ្យា សេចក្តីណែនាំលេខ០០៣ សណនមស.ចុះថ្ងៃទី០៣ ខែមករា ឆ្នាំ២០០១ របស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈស្តីពីការអនុវត្តគោលការណ៍រួមនៃនីតិវិធីគ្រប់គ្រងមន្ត្រីរាជការស៊ីវិល និងសេចក្តីណែនាំលេខ០០១/០៩សណន.ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៩ របស់ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាលស្តីពីការអនុវត្តតារាងទូទាត់បៀវត្សតាមប្រព័ន្ធព័ត៌មានវិទ្យានៅថ្នាក់រាជធានី ខេត្ត រហូតដល់បច្ចុប្បន្ននេះ ទទួលបានលទ្ធផលល្អប្រសើរ។ ទន្ទឹមនឹងនេះ ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាលសង្កេតឃើញថានៅមានបញ្ហាមួយចំនួនដែលនាំឲ្យមានភាពអសកម្ម និងមានការយឺតយូរដល់ដំណើរការអនុវត្តការបើកផ្តល់ប្រាក់បៀវត្ស និងប្រាក់បំណាច់ផ្សេងៗជូនមន្ត្រីរាជការស៊ីវិល។ ដោយមើលឃើញបញ្ហានេះ និងដើម្បីបន្តពង្រឹងការអនុវត្តតារាងទូទាត់បៀវត្សតាមប្រព័ន្ធព័ត៌មានវិទ្យា ក៏ដូចជាការផ្លាស់ប្តូរស្ថានភាពរបស់មន្ត្រីរាជការស៊ីវិល និងការចំណាយលើបៀវត្សឲ្យកាន់មានប្រសិទ្ធភាពថែមទៀតស្របតាមកម្មវិធីជាតិកំណែទម្រង់រដ្ឋបាល២០១០-២០១៣ ដែលបានអនុម័តដោយកិច្ចប្រជុំក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល កាលពីខែតុលា ឆ្នាំ២០១១ កន្លងមក ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាលសូមធ្វើការណែនាំបន្ថែមលើនីតិវិធីអនុវត្តតារាងទូទាត់បៀវត្សតាមប្រព័ន្ធព័ត៌មានវិទ្យាទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិដូចខាងក្រោម ៖

១- ចំពោះថ្នាក់ជាតិ :

- គ្រប់ក្រសួង ស្ថាប័នត្រូវខិតខំបន្តរឹតបន្តឹងការអនុវត្តតាមខ្លឹមសារនៃសេចក្តីណែនាំលេខ ០០៣ សណនមស.ចុះថ្ងៃទី ០៣ ខែ មករា ឆ្នាំ២០០១ របស់រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈស្តីពីការអនុវត្តគោលការណ៍រួមនៃនីតិវិធីគ្រប់គ្រងមន្ត្រីរាជការស៊ីវិល ។
- ចំពោះប្រាក់បំណាច់មុខងារសម្រាប់មុខតំណែងជាអនុប្រធាននាយកដ្ឋាន អនុប្រធានការិយាល័យ អនុប្រធានមន្ទីររាជធានី ខេត្ត និងមុខតំណែងប្រហាក់ប្រហែលដែលមានក្នុងរចនាសម្ព័ន្ធរបស់ក្រសួង ស្ថាប័នអនុញ្ញាតផ្តល់ជូនត្រឹមតែចំនួន ០៣ រូបប៉ុណ្ណោះដោយផ្អែកលើសារាចរណែនាំរបស់រាជរដ្ឋាភិបាលលេខ ០២ សរណន. ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ១៩៩៩ ស្តីពីការជ្រើសរើស និងការតែងតាំងមន្ត្រីរាជការស៊ីវិល សេចក្តីជូនដំណឹងលេខ ១៧៥៨ សជណ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៥ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ស្តីពីការ

ផ្តល់ប្រាក់បំណាច់មុខងារជូនអនុប្រធាននាយកដ្ឋាន និងសេចក្តីជូនដំណឹងលេខ ១២ សជណ. សរ ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០១១ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ស្តីពីលទ្ធផលនៃសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១០ ហើយក្រសួង ស្ថាប័នត្រូវធានាឲ្យមានតម្លាភាព និងជៀសវាងកុំឲ្យមានបាតុភាពផ្ទៃក្នុងស្ថាប័នរបស់ខ្លួន ។

- គ្រប់ក្រសួង ស្ថាប័ន ត្រូវខិតខំបន្តជំរុញការរៀបចំបែបបទដាក់មន្ត្រីរាជការស៊ីវិលដែលដល់អាយុចូលនិវត្តន៍ឲ្យបានទាន់ពេលវេលាស្របតាមស្មារតីនៃអនុក្រឹត្យលេខ ៨០ អនក្រ.បកចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០២ ស្តីពីការគ្រប់គ្រងដំណើរការនៃការដាក់មន្ត្រីរាជការស៊ីវិលឲ្យចូលនិវត្តន៍តាមប្រព័ន្ធព័ត៌មានវិទ្យា។ ក្នុងករណីយឺតយូរហួសកាលកំណត់ អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាលនឹងបន្តដកឈ្មោះមន្ត្រីទាំងនោះចេញពីតារាងទូទាត់បៀវត្សដោយស្វ័យប្រវត្តិ ។ ការដកឈ្មោះមន្ត្រីចេញពីតារាងទូទាត់បៀវត្សពុំមានន័យថា អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល បានដាក់មន្ត្រីដែលត្រូវចូលនិវត្តន៍ឲ្យចូលនិវត្តន៍ជំនួសក្រសួង ស្ថាប័ននោះទេ គឺក្រសួង ស្ថាប័នសាមីត្រូវបន្តរៀបចំបែបបទដាក់មន្ត្រីចូលនិវត្តន៍តាមនីតិវិធីជាធរមាន ។
- ចំពោះសំណើ ឬ របាយការណ៍ស្តីពីការផ្លាស់ប្តូរស្ថានភាពរដ្ឋបាល និងស្ថានភាពគ្រួសាររបស់មន្ត្រីរាជការស៊ីវិលនៅតាមក្រសួង ស្ថាប័នដែលត្រូវឆ្លងការពិនិត្យ និងសម្រេចពីក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល ត្រូវធ្វើឡើងតាមរយៈច្រកចេញ-ចូលតែមួយរបស់អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល ។

២- ចំពោះថ្នាក់ក្រោមជាតិ :

- គ្រប់សាលារាជធានី ខេត្ត និងមន្ទីរជំនាញជុំវិញរាជធានី ខេត្ត ត្រូវខិតខំបន្តរឹតបន្តឹងការអនុវត្តសេចក្តីណែនាំលេខ ០០១/០៩សណន.ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៩ របស់ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល ស្តីពីការអនុវត្តតារាងទូទាត់បៀវត្សតាមប្រព័ន្ធព័ត៌មានវិទ្យានៅថ្នាក់រាជធានី ខេត្ត។ លើកលែងតែករណីការស្នើសុំផ្លាស់ប្តូរស្ថានភាពរដ្ឋបាល និងស្ថានភាពគ្រួសាររបស់មន្ត្រីរាជការស៊ីវិលដែលបានកំណត់ក្នុងចំនុចទី១ និងទី២ នៃសេចក្តីណែនាំខាងលើនេះ ត្រូវឆ្លងកាត់ការពិនិត្យ និងផ្តល់ទិដ្ឋាការពីក្រសួង ស្ថាប័នសាមីដែលជាស្ថាប័ន អាណាព្យាបាលរបស់សាលារាជធានី ខេត្ត និងមន្ទីរ/អង្គភាពជាមុន ទើបបញ្ជូនទៅការិយាល័យបៀវត្សពលកម្មនៃមន្ទីរផែនការរាជធានី ខេត្ត ដើម្បីបញ្ជាក់ និងប្រមូលផ្តុំ ព្រមទាំងចាត់ចែងបន្តជាមួយអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល ។ ក្នុងន័យនេះការិយាល័យបៀវត្សពលកម្មនៃមន្ទីរផែនការរាជធានី ខេត្ត ពុំមានសិទ្ធិផ្តល់ទិដ្ឋាការលើរបាយការណ៍សុំផ្លាស់ប្តូរស្ថានភាពរដ្ឋបាល និងស្ថានភាពគ្រួសាររបស់មន្ត្រីនៃសាលារាជធានី ខេត្ត និងមន្ទីរ/អង្គភាពជំនាញទៀតឡើយ ។
- ដោយឡែកមន្ត្រីរាជការស៊ីវិលនៅថ្នាក់ក្រោមជាតិដែលត្រូវបានតែងតាំងមុខតំណែងខ្ពស់ស្របតាមរចនាសម្ព័ន្ធថ្នាក់កណ្តាលបន្ថែមលើមុខងារបច្ចុប្បន្ន ជាគោលការណ៍មន្ត្រីទាំងនេះត្រូវទទួលបានប្រាក់បំណាច់មុខងារតែមួយប៉ុណ្ណោះ។ រីឯការបញ្ចូលប្រាក់បំណាច់មុខងារទៅក្នុងតារាងទូទាត់បៀវត្ស ចាំបាច់ត្រូវមានការទទួលស្គាល់ ឬ ផ្តល់ទិដ្ឋាការពីប្រធានស្ថាប័នសាមីមន្ត្រីជាមុនសិន ហើយប្រាក់បំណាច់មុខងារនេះត្រូវគិតបញ្ចូលនៅក្នុងកញ្ចប់ថវិការបស់សាលារាជធានី ខេត្ត ឬ មន្ទីរ/អង្គភាពជំនាញរបស់សាមីមន្ត្រី ។
- សំណើ ឬ របាយការណ៍ស្តីពីការសុំផ្លាស់ប្តូរស្ថានភាពរដ្ឋបាល និងស្ថានភាពគ្រួសារប្រចាំខែ ឬ ត្រីមាសរបស់មន្ត្រីរាជការស៊ីវិលនៅថ្នាក់ក្រោមជាតិដែលត្រូវឆ្លងការពិនិត្យ និងសម្រេចពីក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល ត្រូវអនុវត្តដូចគ្នានឹងការអនុវត្តរបស់ក្រសួង ស្ថាប័នថ្នាក់កណ្តាលដែរ ។

៣- រាល់សំណើសុំផ្លាស់ប្តូរស្ថានភាពរដ្ឋបាល និងស្ថានភាពគ្រួសាររបស់មន្ត្រីរាជការស៊ីវិលទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ចាំបាច់ត្រូវមានភ្ជាប់ឯកសារពាក់ព័ន្ធដែលបញ្ជាក់ពីស្ថានភាពក្របខណ្ឌ និងកាំប្រាក់បៀវត្សចាស់របស់មន្ត្រី និងក្របខណ្ឌឬកាំប្រាក់បៀវត្សថ្មីដែលត្រូវស្នើសុំផ្លាស់ប្តូរ។ ឯកសារពាក់ព័ន្ធទាំងអស់ដែលត្រូវភ្ជាប់ជាមួយការស្នើសុំផ្លាស់ប្តូរស្ថានភាពរបស់មន្ត្រីរាជការ ត្រូវជាឯកសារដែលមានបោះត្រាក្រហម និងមានបញ្ជាក់ពីភាពត្រឹមត្រូវតាមច្បាប់ដើម ។

ទទួលបានសេចក្តីណែនាំនេះ គ្រប់ក្រសួង ស្ថាប័ន និងសាលារាជធានី ខេត្ត ព្រមទាំងមន្ទីរ/អង្គភាពជំនាញជុំវិញរាជធានី ខេត្ត ត្រូវសហការ និងចាត់តាំងអនុវត្តឲ្យមានតម្លាភាព ប្រសិទ្ធភាព និងការទទួលខុសត្រូវខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៤ ខែ ០៧ ឆ្នាំ ២០១២

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
**និងជាប្រធានក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល**

**សុខ អាន**

<u>ចម្លងជូន</u> :
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន " ដើម្បីអនុវត្ត "
- គ្រប់សាលារាជធានី ខេត្ត " ដើម្បីអនុវត្ត "
- គ្រប់មន្ទីរ/អង្គភាពជំនាញជុំវិញរាជធានី ខេត្ត " ដើម្បីអនុវត្ត "
- ឯកសារ - កាលប្បវត្តិ